**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីថ្លែងការណ៍

យោងតាមការព្រមព្រៀងដែលធ្វើឡើងរវាងគណៈបក្សនយោបាយធំៗទាំងពីរ កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ កន្លងទៅ បានផ្តល់ឱកាសឲ្យរូបខ្ញុំត្រូវបានជ្រើសរើសជាសមាជិកទី៩ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី (គ.ជ.ប)។

នៅខណៈនោះ តួនាទីជាសមាជិកទី៩សម្រាប់ខ្ញុំគឺ"......ជាសមាជិកឯករាជ្យម្នាក់ ពិតជានឹងរួមវិភាគទានយ៉ាងសំខាន់ដល់អព្យាក្រឹតភាពនៃស្ថាប័នរៀបចំការបោះឆ្នោត ដើម្បីសម្រេចបេសកកម្មរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន"។

មកដល់ថ្ងៃនេះ រូបខ្ញុំជឿជាក់ថា មុខណែងមួយនេះ ខ្ញុំមិនអាចអនុវត្តទៅរួចនោះទេ។

ការដែលត្រូវបានជ្រើសរើសសម្រាប់មុខតំណែងដ៏សំខាន់នេះ គឺជាកិត្តិយសដ៏ខ្ពង់ខ្ពស់សម្រាប់រូបខ្ញុំ តែគួរឲ្យសោកស្តាយ ខ្ញុំមិនអាចទទួលយកតំណែងជាសមាជិកទី៩ នៃគ.ជ.ប ថ្មីនេះបានទេ ។

ខ្ញុំសូមអភ័យទោសដល់បងប្អូនជនរួមជាតិទាំងឡាយដែលមានជំនឿលើខ្ញុំ ហើយដែលអាចមានការខកចិត្តដោយសារការសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥

ទំនាក់ទំនងលោកស្រីវេជ្ជ. ពុង ឈីវកេក
ទូរស័ព្ទលេខ ០១២ ៨០២ ៥០៦